***អ្នកដាំគួរដឹង*** : *ត្រកួនគោកអាចដាំបានគ្រប់រដូវឲ្យតែដីធ្លាមានជីជាតិ និងមានទឹកគ្រប់គ្រាន់។*

## ៤.ការធ្វើរងដាំ

- ឧបករណ៍រៀបចំដី និងជីទ្រាប់បាតរង - ចបជីក ចបកាប់ - រនាស់ដៃ បង្គី
- ខ្សែម៉ែត្រ - បង្គោលចុងស្រួច - ដីកំប៉ុស្ត ដីលាមកសត្វ






### ៤.១. ការធ្វើរងដាំនៅរដូវវស្សា

១- កាប់ដីហាលរយៈពេល១០ថ្ងៃ ទុកឲ្យស្ងួត ទើបវាយបំបែកដីឲ្យម៉ដ្ឋ ។

២- លើករងត្រកួនដែលមានទទឹង១ម៉ែត្រកំពស់១តឹកកន្លះទៅ២តឹក ឯបណ្ដោយអាស្រ័យទៅតាមស្ថានភាពដីវែង ឬខ្លី។

**ហេតុអ្វីត្រូវលើករងឲ្យខ្ពស់នៅរដូវវស្សា?**

ដើម្បីការពារទឹកដក់ ឬលិចរង ពេលមានភ្លៀងធ្លាក់ជោកជាំ ។

### ៤.២. ការធ្វើរងដាំនៅរដូវប្រាំង

១- កាប់ដីហាលតែរយៈពេល ១អាទិត្យ បន្ទាប់មកវាយបំបែកដីឲ្យម៉ដ្ឋ។

២- លើករងដាំដែលមានទទឹង ១ម៉ែត្រ កំពស់១តឹក និងបណ្ដោយអាស្រ័យទៅតាមស្ថានភាពដីវែង ឬខ្លី។

## ៥. ការដាក់ជីទ្រាប់បាត

១- យកជីកំប៉ុស្ត ឬជីលាមកសត្វផ្សេងៗ ដែលពុកផុយមករោយពីលើរង។

២- យកចបកាប់មកជ្រំៗដីត្រឡប់សារចុះសារឡើង ដើម្បីឲ្យជីចូលទៅក្នុងដី។

៣- យករនាស់ដៃមករាស់ដីឲ្យបានស្មើល្អ ។

**អ្នកដាំគួរដឹង**

- *ត្រូវរោយជីកំប៉ុស្ត ឬជីអាចម៍គោដែលពុកផុយ ចំនួនពី ៣ ទៅ៥គីឡូ នៅលើដីមួយម៉ែត្របួនជ្រុង ។*
- *មិនត្រូវយកជីកំប៉ុស្តទៅចាក់គរទុកចោលនៅលើរង ដោយមិនជ្រំត្រឡប់នោះទេ ព្រោះវាធ្វើឲ្យសារធាតុចិញ្ចឹមនៅក្នុងជីហើរទៅតាមខ្យល់។*

ដើម្បីឲ្យគ្រាប់ពូជដុះបានល្អ យើងត្រូវយកគ្រាប់ពូជណាដែលគ្មានជម្ងឺ គ្មានការបំផ្លាញពីសត្វល្អិត និងមិនទុកយូរឆ្នាំ។